ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ០០៤ សស.អឃស

ថ្ងៃអង្គារ ៨ រោច ខែ បុស្ស ឆ្នាំ រកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០១៨.

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ជម្រាបជូន**
**លោក លោកស្រីប្រធានក្រុមហ៊ុនផលិតផលថ្នាំជក់ក្នុងព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖ សេចក្តីណែនាំអំពីការបោះពុម្ពគំរូសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព ទំហំ៥៥% លើកញ្ចប់ផលិតផលថ្នាំជក់ ។**

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបលោក លោកស្រី ជ្រាបថា ក្រសួងសុខាភិបាលបានចេញគំរូសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពទំហំ៥៥%ថ្មីចំនួនពីរ ដែលត្រូវជំនួសពីលើគំរូសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពចាស់ចំនួនពីរ ដែលកំពុងចរាចរនៅលើទីផ្សារនាពេលបច្ចុប្បន្ន។ គំរូសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពថ្មីនេះ **គឺជក់បារីបណ្តាលឱ្យដាច់សរសៃឈាមខួរក្បាល និងជក់បារីបណ្តាលឱ្យកើតជំងឺសរសៃឈាមសើស្បែក។**

ការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពថ្មីទាំងពីរខាងលើ នឹងត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ និងតម្រូវឱ្យកញ្ចប់បារីទាំងអស់ដែលចរាចរនៅលើទីផ្សារត្រូវមានសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពថ្មី ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨ ខាងមុខនេះ។ ដូចនេះ លោក លោកស្រី អាចយកទៅបោះពុម្ពតាមទំហំនៃឧបករណ៍វេចខ្ចប់ផលិតផលថ្នាំជក់របស់ខ្លួន ដោយរក្សាទំហំរូបភាព៥៥% ផ្នែកខាងលើ លើផ្ទៃសំខាន់ខាងមុខ និងផ្ទៃសំខាន់ខាងក្រោយ ឬនៅលើផ្ទៃសំខាន់ទាំងអស់ប្រសិនកញ្ចប់មានផ្ទៃលើសពីពីរ។ ម្យ៉ាងទៀតសារជារូបភាពត្រូវមានសភាពច្បាស់ដូចរូបភាពដើមដែលមានក្នុងឧបសម្ព័ន្ធទី៣ និងទី៤ នៃប្រកាស។

អាស្រ័យហេតុនេះ សូមលោក លោកស្រី មេត្តាអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ម៉ម ប៊ុនហេង**

**<u>ចម្លងជូន</u>**
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- សមាជិកគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់
"ដើម្បីជ្រាប និងសហការ"
- ឯកសារ-កាលប្បវត្តិ

ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩